អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងតំរៀបនៅលើគំនូសក្នុងក្រដាស**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយការសង្កេត)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**បុរេគណិត**

រូបរាង និងលំហ (បញ្ញត្តិរូបរាង និងលំហ)

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ។
ប្រាប់ពីការដើរ ឬ លើសពីនេះទៅតាមទម្រង់នៃសកម្មភាពផ្សេងៗ។

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីឈ្មោះសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាបឬលើសពីនេះ។

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបធ្វើសកម្មភាពបង្កើតបានជារូបភាពផ្សេងៗ។

**(បុរេគណិត)** ប្រាប់ឈ្មោះរាងធរណីមាត្រសមញ្ញៗមានរាងធរណីមាត្ររាងរង្វង់ ការេ ត្រីកោណ មូលទ្រវែង ចតុកោណកែង ចតុកោណស្មើ បេះដូង ផ្កាយ ។
ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សន្លឹកកិច្ចការ (ធំ, តូច) គ្រាប់ សណ្តែក អង្គរ ស្រូវ

**ការរៀបចំ** ៖ បោះពុម្ពក្រដាសរូបភាពឱ្យក្មេងម្នាក់ ១សន្លឹកៗ ឱ្យកុមារយកគ្រាប់ សណ្តែក អង្ករ ស្រូវតាមផ្ទះមកក៏បាន ប្រើការប្រភេទដែលមិនមានគ្រោះថ្នាក់ដល់ក្មេង ឬ មិនចាំបាច់ប្រើការបិតក៏បាន។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងតំរៀបនៅលើគំនូសក្នុងក្រដាស**ជាមួយកូនៗទាំងអស់គ្នា។
2. យករូបភាពក្នុងរឿង **"យក្សចម្លែក"** ដែលមានសត្វខូអាឡាមកបង្ហាញក្មេងៗ។
3. កូនៗតើរូបភាពនេះជាសត្វអ្វី? បាទ/ចាស ជាសត្វខូអាឡា
4. តើសត្វខូអាឡាមាននៅក្នុងប្រទេសណា? បាទ/ចាស សត្វខូអាឡាមាននៅក្នុងប្រទេសអូស្រ្តាលី។
5. តើសត្វខូអាឡានៅរឿង " យក្សចម្លែក" ឈ្មោះអ្វី? បាទ/ចាស សត្វខូអាឡាមានឈ្មោះ ខេទី។
6. តើកូនៗចង់បង្កើតសត្វខូអាឡាជាមួយអ្នកគ្រូដែរឬទេ? បាទ/ចាស
7. ត្រូវយកការស្អិតលាបតាមរាងអក្សរនិងរូបភាពសត្វខូអាឡា.
8. សូមកូនៗតម្រៀបតាមរាងសត្វខូអាឡា
9. ចាប់ផ្តើមចែកក្រដាសរូបភាពសត្វខូអាឡាឱ្យទៅក្មេងៗម្នាក់ ១សន្លឹក ។
10. បន្ទាប់មក យកឈើចង្កឹះជ្រលក់ការបន្តិច ហើយចាប់យកគ្រាប់សណ្តែក
11. ម្តងមួយគ្រាប់ៗដើម្បីដាក់តម្រៀបតាមគំនូសពាក្យខូអាឡានិងសត្វខូអាឡា
12. ការស្អិតត្រូវលាបវាឱ្យសព្វតាមគំនូសពាក្យខូអាឡានិងសត្វខូអាឡា
13. បិទបែបនេះឱ្យពេញតាមរូបភាពក្នុងក្រដាសគឺជាការស្រេច។

**ការប្រែប្រួលៈ**

១. ប្រសិនបើអ្នកមិនមានពេលច្រើនទេ អ្នកអាចលេងជាក្រុមរួមគ្នាមួយថ្នាក់ក៏បានដោយប្រើសន្លឹកកិច្ចការសត្វខូអាឡាមួយសន្លឹក ឱ្យក្មេងៗឡើងតម្រៀបម្នាក់ម្តង ដាក់សណ្តែកម្នាក់មួយគ្រាប់ជារង្វិលជុំ រហូតចេញជាសត្វខូអាឡា។

២. បើមិនមានពេលគ្រប់គ្រាន់ទេ អាចឱ្យកុមារតម្រៀបគ្រាប់សណ្តែកតែ ត្រចៀក ច្រមុះ ក្បាល ឬ ចំណុចណាដែលអ្នកគិតថាសំខាន់ក៏បាន។